# សិលាចារឹកប្រាសាទស្ទឹងខាងកើត K.៨៧៩

ប្រាសាទស្ទឹងខាងកើត មានទីតាំងស្ថិតមានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង។ ប្រាសាទនេះកសាងឡើងអំពីឥដ្ឋ មានគ្រឿងលម្អស្ថាបត្យកម្មធ្វើពីថ្មភក់ បែរមុខទៅទិសខាងកើត។ សិលាចារឹកប្រាសាទស្ទឹងខាងកើត រកឃើញនៅផ្នែកខាងក្រោយនៃបន្ទះផ្តែររបស់ប្រាសាទ ដែលទំនងជាពីមុនមកគឺជាសិលាចារឹកពេញលេញមួយ ហើយសម័យក្រោយមកគេបានកែប្រែមុខងារទៅជាផ្តែរទ្វាររបស់ប្រាសាទ។ សិលាចារឹកនេះ ធ្លាប់សិក្សា និងបោះពុម្ពផ្សាយដោយលោក ហ្សក សឺដេស នៅក្នុងឆ្នាំ១៩៥៣។

ចំណុចដ៏គួរឱ្យចាប់អារម្មណ៍មួយគឺ នៅក្នុងសិលាចារឹកបានបញ្ជាក់អំពីស្រុកមួយដែលមានឈ្មោះថា "ស្រុកជ្រៅវាកស្ទេង" ដែលអាចត្រូវនឹងសម័យទំនើបថា "ស្រុកជ្រៅពាក់ស្ទែង"។ ដូច្នេះ ឈ្មោះ "ស្ទឹង" ប្រហែលជាពាក្យក្លាយមកពីសំនៀងដើមថា "ស្ទេង" ហើយនៅក្បែរនោះក៏មានស្ថាននាមស្រដៀងគ្នាដែរគឺ "ពាក់ស្បែក"។ ប៉ុន្តែ អ្នកស្រុកនិទានរឿងដែលទាក់ទងនឹងឈ្មោះនេះថា "កាលដើមទីតាំងនេះជាកន្លែងដែលគេបោះស្នឹងដើម្បីចងគោ"។

សិលាចារឹកនេះនៅមានគុណភាពល្អនៅឡើយ ដែលយើងអាចអានបានស្ទើរតែទាំងអស់ លើកលែងតែផ្នែកដែលរលុបខ្លាំង។ អត្ថបទសិលាចារឹកប្រាសាទស្ទឹងខាងកើត ចារឹកឡើងជាពីរភាសា សរុបចំនួន ៣៨ បន្ទាត់ គឺភាសាសំស្ក្រឹតចំនួន ២ បន្ទាត់ (បន្ទាត់ទី១ ដល់ទី២) និងភាសាខ្មែរបុរាណចំនួន ៣៦ បន្ទាត់ (បន្ទាត់ទី៣ ដល់ទី៣៨)។

ក្នុងនោះ ចារឹកភាសាសំស្ក្រឹតនៅពីរបន្ទាត់ខាងលើសរសេរជាស្លោកសំស្ក្រឹតប្រភេទអតិសក្វរីឆន្ទ ឈ្មោះថា "មាលិណី" មានចំនួន ១៥ ព្យាង្គ ដែលអត្ថន័យជារួមរៀបរាប់អំពី រាជ្យមន្ត្រីម្នាក់របស់ព្រះបាទកម្រតេងកំត្វនអញស្រីសូយ៌្យវម៌្មទេវ (ព្រះបាទសូរ្យវរ្ម័នទី១) មានឋានៈជារាជអាមាត្រ ដែលមាននាមថា "គុណបតិវម៌្ម" បានថ្វាយតង្វាយចំពោះព្រះស្រីឃនៈជាម្ចាស់។ ចំណែកអត្ថបទចារឹកជាភាសាខ្មែរបុរាណ រៀបរាប់អំពីតង្វាយរបស់មន្ត្រីមួយចំនួន ដូចជា ព្រះកម្រតេងអញស្រីសមរសិទ្ធវម៌្ម ព្រះកម្រតេងអញស្រីករិន្ទ្រវិជយ ព្រះកម្រតេង........... ថ្វាយទៅដល់អាទិទេពនៅច្បារឫស្សី(កម្រតេងជគតច្បារឫស្សី) ដែលតង្វាយទាំងនោះសុទ្ធសឹងជាអ្នកបម្រើប្រុសស្រីដែលមានរៀបរាប់ឈ្មោះភ្ជាប់មកជាមួយសិលាចារឹកស្រាប់។ តាមរយៈអត្ថន័យរបស់សិលាចារឹក

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*នេះ យើងដឹងថា ព្រះកម្រតេង អញស្រីសមរសិង្ហវម៌្ម មកពីស្រុកស្តុកស្តុត ព្រះកម្រតេងអញស្រីក វិន្ទ្រវិជយ មកពីស្រុកជ្រៃវាក ស្ទេង (ជ្រៃពាក់ស្ទែង)។*

**អត្ថបទពាក្យចារឹក**

១. ជរណិជរវរាជ្ក័ច្រោល្វសទ្រេត្តរេចី      រចិតឯ៦រុចេក ត្រីសូយ៌្យវម៌្ម.........

២. សចិរ ឥវ ជនេកត្រ្កឹយនេ ត្រីកុណាជ្យោ..   ជិតកុណាបតិវម៌្ម..........................។

៣. //៩៦២ ឝក បញ្ចមិ រោច អាមាឍ វ្ឫហស្បតិវារតិន្ទុវ្រះកម្រតេងអញ

៤. ត្រីសមរសិង្ហវម៌្ម ស្រុក ស្តុក ស្តុត សមយុក ទុ វ្រះកម្រតេងអញ ត្រី

៥. កាវិន្ទ្រវិជយ ស្រុក ជ្រៃ វាក ស្ទេង៍ ភគវឞ មជ្យាហ្ន វ្រះ ត្រី.....

៦. វ្រះកម្រតេង៍អញ តបស្វី អ្វល ទុ ប្បុមប្រែជានដោង៍បិ ថ្ងៃ .....

៧. ត វ្រះ រូប កម្រតេង៍ ជគត ច្បា វឡ្បិ តិ ស្ថាបជា អាយ លង្វ័....

៨. តៃ បរោង៍ ក្វន យោ វ្វី តៃ ខ្ទិចតៃកញ្ជោំតៃថ្ការយោគំវិត តៃ......

៩. ម្វល យោ កញ្ចែ យោ កុមារ ខោ ប្ញិ យោ គំវៃ តៃ ថ្ប្ញក តៃ ផ្គោ យោ ...............

១០. តៃ បរោង៍ តៃ គំវិច តៃ ត្រេម្ព តៃ ថ្ពោន យោ លង្ក្ស តៃ គំវ្រះ.......

១១. តៃ កញ្ជា តៃ កញ្ជុ តៃ តន្វ យោ កញ្ចាន យោ គំបិត តៃ កន្រ្តុត តៃ..........

១២. តៃ ថ្ងៃ តៃ ប ...តៃ វុទ្ធិរ តៃ កញ្ជោំ យោ គំវ្រះ យោ គំវៃ តៃ ក្រាញ ..........

១៣. តៃ ថ្ងៃ តៃ គំព្រៅ តៃ កន្ទាន តៃ កញ្ជាន តៃ ក្រាញ តៃ បន្ទាន តៃ..

១៤. តៃ ភទ្រ តៃ កញ្ជោ យោ គំផល តៃ កញ្ជោំ តៃ ផ្គង៍ យោ លឃុ...

១៥.  កាន៦ តៃ កន្វត .តៃ..ឥ យោ តន្ទាន យោ កន្រែន យោ ខ្ទិត យោ ក .........

១៦. តិថ៌ យោ កញ្ជាន តៃ កាន៦ តៃ  គំវិច ◦ យោ គំវៃ តៃ វ្រហ្ម .........

១៧. តៃ ផ្គោ ◦ តៃ ត្រេម្ព តៃ តំញ្យល តៃ កន្វត ◦ តៃ កញ្ជាន តៃ ស្វាស្រែ..

១៨. កញ្ជាន ក្វន យោ វរិ យោ កញ្ចែង៍ ◦ តៃ គំវៃ តៃ ត្រាវង  តៃ ថ្ប្ញក យោ ...........

១៩. តៃ គំវិត តៃ ថ្ការ តៃ កញ្ជុ ក្វន យោ ស្វាស្តិ តៃ កន្ធិ ក្វន តៃ កន្វន តៃ .........

២០. តៃ ជឯម យោលាភ យោថច ទុយុក តៃ កញ្ចាន យោសំអប យោ ហរិ យោ .........

២១. តៃ តន្វ យោ តន្ទាន យោ កញ្ជាន យោ គំវៃ តៃ កញ្ជុ តៃ គំបិត តៃ ចំ ........

២២. ម្ទ តៃ ឃុល យោ កញ្ជេស តៃ បរោង៍ យោ បមេក យោ គំវ្រះ យោ ជៃ........ក

២៣. ញ្ជុ យោ កញ្ជុក យោ កញ្ជុក យោ បន្វស យោ តន្ទា យោ កន្ត្រី យោ ........ក

២៤. យោ ល្វន តៃ កញ្ជាន តៃ ផ្គោ យោ កញ្ចែ តៃ ស្វស្តិ តៃ កញ្ជុ យោ គំ ...........

២៥. ចាម្ប តៃ វំដា យោ កញ្ជុក តៃ កញ្ជុ តៃ កន្តំ តៃ វ្រហ្ម តៃ ...........

២៦. បុន យោ អាទិត្យ តៃ គំព្រៅ តៃ ថ្ងៃ យោ កញ្ចោង៍ យោ គំវុត .......

២៧. កម្តី យោ គំព្រៅ យោ ខ្ន យោ កន្តែ្យល តៃ បរោង៍ តៃ កន្ទ្យង៍ យោ .....ក

២៨. ញ្ជាន តៃ កន្ធី តៃ គំវិត តៃ កញ្ជាន តៃ កន្ត្រី អ្ន កលឱះ តៃ.........

២៩. យោ កន្ធស យោ កញ្ជាន យោ កន្ទុ យោ ជេង៍ វ្នំ យោ កន្ទេប តៃ .........

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

៣០. តៃ កាឡ្បាន ក្វន យោ កាឡ្បាន យោ ក្រ្វច អ្មេ កាង្វេជ តៃ កា ......ប
៣១. ពេជ តៃ ថ្ងៃ តៃ ឥស លេហ តៃ បពេជ តៃ បង្វាន តៃ កាជ្រៃ ....
៣២. តៃ កាន្ទូត យោ កាញ្ជៅ តៃ ខ្នុច ក្វន ដោះតៃ..............
៣៣. កាង្សោ តៃ កាឡ្បាន យោ កាឡ្ហាត ◦ តៃ ថ្នាស តៃ ..........
៣៤. ៩៦៣ឥកា ◦ បិពេច ដេម្ន ចាន្ទ្រវារ ទុ វ្រះកាម្រតេជ............
៣៥. ........ខ្ញុំ បិ ថ្វន ត កាម្រតេជ ជគត ឆ្បារ វង្សិ ត កា.............
៣៦. .......យោ ១.....យោ ដិរ យោ កាន្តី

**បំណកប្រែ**

*(១–២) គុណបតិវម៌្ម ជាអ្នកមាននូវគុណធម៌ សីលធម៌ ចរិយាធម៌ បានផ្ដល់តង្វាយចំពោះព្រះស្រីឃនៈ ដូចជាធនេស (ជាស្ដេចនៃទ្រព្យសម្បត្តិ=កុវេរៈ)។ គាត់ជាពាជ្យអាមាត្យរបស់ព្រះករុណាព្រះបាទស្រីសូយ៌្យវម៌្ម (ព្រះបាទសូរ្យវរ្ម័នទី១) ទ្រង់លម្អដោយព្រះស្រីនខៈ (លម្អនៃក្រចក) ប្រដាប់ដោយសិរីរតនៈដ៏ភ្លឺថ្លានៅលើក្អំ គឺជាពង់កាយដ៏ប្រសើរ។*

*(៣–៣៣) នៅក្នុងឆ្នាំ ៩៦២ នៃមហាសករាជ (ត្រូវនឹងគ.ស.១០៤០) ៥រោច ខែអាសាឍ ថ្ងៃព្រហស្បតិ៍ **ព្រះកម្រតេងអញស្រីសមរសិង្ហវម៌្ម** ស្រុកស្ដុកស្ទុត សមយុគ និង**ព្រះកម្រតេងអញស្រីកវិន្ទ្រវិជយ** ស្រុកជ្រៃវាកស្នេង ភគវន នៅចំពាក់កណ្ដាលថ្ងៃនៃ **ព្រះស្រី**..........**ព្រះកម្រតេងអញ** **តបស្វី**គ្រប់ចំនួនទាំងអស់ និងបុរសជាប្រធានផង មកធ្វើនូវ........ ចំពោះ**ព្រះរូបកម្រតេងជគតច្បារឬស្សី** ដែលបានស្ថាបនាសាងសង់ឡើងនៅឯលង្វ........។ តង្វាយថ្វាយចំពោះព្រះរួមមាន៖ អ្នកបម្រើស្រីប្រុសឈ្មោះ តៃបពេង កូន យោវ្វី តៃខ្មិច តៃកន្សោរាំ តៃថ្កុវ យោកំវិត តៃ......មូល យោកញ្ចៃ យោកុមារខោឬមិ យោកំរៃ តៃថ្ព្យក តៃឆ្កេ យោ..... តៃបពេង តៃកំវិច តៃគ្រម្ម តៃថ្កោន យោលង្ហុះ តៃកំវ្រះ.......តៃកញ្ជា តៃកញ្ចុ តៃគន្ធ យោកញ្ចាន យោកំបិត តៃកទ្រុត តៃ......តៃថ្ងៃ តៃប ...តៃរុទ្ធិរ តៃកន្សោរាំ យោកំវ្រះ យោកំរៃ តៃក្រញ ......តៃថ្ងៃ តៃកំព្រៅ តៃកន្ទាន តៃកន្សាន តៃក្រញ តៃបន្ទាន តៃ..តៃកទ្រ តៃកន្សោ យោកំផល តៃកន្សោរាំ តៃផ្គង យោលឃុ...កនឪ តៃកន្ទុត .តៃ..ឥ យោគន្ទាន យោកទ្រន យោខ្មិត យោក .....តៃកនឪ តៃកំវិច យោកំរៃ តៃវ្រហ្ម .....តៃឆ្កេ តៃគ្រម្ម តៃតំន្សល តៃកន្ទុត តៃកន្សាន តៃស្វាស្រ..កន្សាន កូន យោរវិ យោកញ្ចេង តៃកំរៃ តៃគ្រាវន តៃថ្ព្យក យោ..... តៃកំវិត តៃថ្ការ តៃកន្សុ កូន យោស្វាស្តិ តៃកន្ធិ កូន តៃកន្ធន តៃ .... តៃផឯម យោលាភ យោថច នុ យុគ តៃកញ្ចាន យោសំអប យោហរិ យោ .....តៃគន្ធ យោគន្ទាន យោកន្សាន យោកំរៃ តៃកន្សុ តៃកំបិត តៃចំ ....ម្ន តៃឃុល យោកន្សេស តៃបពេង យោបមេក យោកំវ្រះ យោផៃ........កន្សុ យោកន្សុក យោកន្សុក យោបន្ទស យោគន្ធា យោកន្តី យោ ........កយោល្វន តៃកន្សាន តៃឆ្កេ យោកញ្ចៃ តៃស្វស្តិ តៃកន្សុ យោកំ .....ចាម្ប តៃវំផា យោកន្សុក តៃកន្សុ តៃកន្តែ តៃវ្រហ្ម តៃ .....បុន*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

*យោអាទិត្យ តៃកំព្រៅ តៃថ្ងៃ យោកញ្ជោង យោកំរុត .....កម្ពី យោកំព្រៅ យោខ្ន យោកន្ទ្យល តៃបរោង តៃកន្ទ្យង យោ .....កន្សាន តៃកន្ទី តៃកំរិត តៃកន្សាន តៃកន្ដី អ្នកលឱះ តៃ.....យោកន្ធស យោកន្សាន យោកន្ទុ យោដេងវ្នំ យោកន្ទេប តៃ ....តៃកន្សាន កូន យោកន្សាន យោក្រូច អ្ន កន្ទេង តៃ ក ...បរោង តៃថ្ងៃ តៃឥសលេហ តៃបរោង តៃបន្ទាន តៃកទ្រៃ ....តៃកន្ទូត យោកញ្ជោ តៃខ្នច កូន នោះ តៃ......កន្សៃ តៃកន្សាន យោ កន្ធាត តៃ ថ្នាស តៃ .........។*

*(៣៤–៣៦) នៅក្នុងឆ្នាំ៩៦៣ នៃមហាសករាជ (ត្រូវនឹងគ.ស.១០៤១) ៣រោច ខែជេស្ឋ ថ្ងៃចន្ទ* ***ព្រះកម្រតេង****......ខ្ញុំបម្រើដែលថ្វាយចំពោះ* ***ព្រះកម្រតេងជគតច្បារឫស្សី*** *(មាន) .....យោ ខ..... យោជិវ យោកន្សី ។*

*ជារួមមក សិលាចារឹកប្រាសាទស្ទឹងខាងកើត បានផ្ដល់ទិន្នន័យផ្នែកប្រវត្តិសាស្ត្រមួយចំនួន ដែលឱ្យយើងដឹងអំពីឈ្មោះរបស់មន្ត្រីសំខាន់ៗក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ និងស្គាល់អំពីឈ្មោះអ្នកបម្រើប្រុសស្រីជាច្រើននាក់។ ឈ្មោះប្រាសាទ កាលបរិច្ឆេទរបស់សិលាចារឹក និងស្ថាបត្យកម្ម ហាក់មានភាពស៊ីគ្នាច្រើន ព្រោះតាមការសន្និដ្ឋានកន្លងមកប្រាសាទនេះអាចសាងឡើងនៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២ ដល់១០៤៩)។ ដូច្នេះហើយ ប្រសិនបើសិលាចារឹកនេះអាចជម្លៀសមកពីដទៃមុននឹងក្លាយមុខងារជាផ្ដែររបស់ប្រាសាទនេះក៏ដោយក្ដី ក៏ប្រហែលជាមិនឆ្ងាយពីទីតាំងដើមនេះដែរ។*

## *ឯកសារយោង*

Coedès, G. 1953. *Inscription du Camdodge,* Tome IV, pp.235, Hanoi.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ ប្រាសាទស្ទឹងខាងកើត មើលពីទិសខាងកើត (រូបភាព៖ លាក់ ស៊ីផាន់ណា)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ២៖ ក្រដាសផ្តិតសិលាចារឹកប្រាសាទស្ទឹងខាងកើត (ផ្តិត៖ កំ វណ្ណាភ៉)

អត្ថបទដោយ៖ កំ វណ្ណាភ៉